**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ៣១២ អក

ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩

សាលក្រមព្រហ្មទណ្ឌលេខ ១៣២ "ណ"

ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

# តាមនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនាថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ ដែលមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៣១២ អ.ក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទឈ្មោះ [redacted] សុធាវី ភេទស្រី អាយុ ៥១ ឆ្នាំ សញ្ជាតិខ្មែរ ទីលំបច្ចុប្បន្ននៅ [redacted] ខេត្តកណ្ដាល ជានីតិជន ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទៈ **បំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម** ប្រព្រឹត្តនៅភូមិអង្គរជ័យ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥២ នៃច្បាប់ភូមិបាល ។

ដែលមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុធាវី ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជូរហុង មានទីលំនៅបច្ចុប្បន្ននៅភូមិព្រែក សង្កាត់ច្បាររំពៅទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ដែលមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជូរហុង ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទខាងលើមានដូចតទៅ៖**

កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧ ស្ថិតនៅភូមិអង្គរជ័យ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល មន្ត្រីរបស់ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់ អភិបាលរងខេត្តកណ្ដាល និងមន្ត្រីសុរិយោដីខេត្តកណ្ដាល បានចុះអនុវត្ត ស.ជ.ណ លេខ ២៣ និងលេខ ០៦២ ពាក់ព័ន្ធនិងដីរបស់ឯកឧត្តម [redacted] ហួរ ដែលមានព្រំប្រទល់ជាប់នឹងដីរបស់ឈ្មោះ [redacted] ជាន់ហុង ដែលមានទំហំ ១៦៧.០៥០២ ហិកតា (មួយរយហុកសិបប្រាំពីរហិកតា ចុចប្រាំរយពីរម៉ែត្រការ៉េ) ខណៈនោះស្រាប់តែជនសង្ស័យឈ្មោះ [redacted] សុធាវី បានចេញមកចង្អុលបង្ហាញគណៈកម្មការថាដីទំហំ ១៦៧.០៥០២ ហិកតាជាដីរបស់គាត់ទៅវិញ ។

-បានឃើញ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២២១ ដកសស ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់តំណាងអយ្យការសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៨៤៧ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៩៣១ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះ លេខ ៨៧៧ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

## នាពេលសវនាការ

១. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផូហុង បានឆ្លើយថា៖ ខ្លួនសុំប្តឹងពីឈ្មោះ [redacted] សុធារី ភេទស្រី អាយុ ៥១ ឆ្នាំ ពាក់ព័ន្ធនឹងករណី ផ្តល់សក្ខីកម្មក្លែង លួចធ្វើប័ណ្ណកម្មសិទ្ធ លើដីកម្មសិទ្ធិរបស់ខ្លួន និងរំលោភកាន់កាប់ដីរបស់ខ្លួន ។ ដីទំហំ ១៦៧,៥០២ ហិកតា (មួយរយហុកសិបប្រាំពីរហិកតា ចុចប្រាំរយពីរម៉ែត្រការ៉េ) ស្ថិតនៅភូមិខ្សុំ បច្ចុប្បន្នស្ថិតនៅភូមិអង្គរជ័យ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលបានទិញពីប្រជាពលរដ្ឋចាប់តាំងពីឆ្នាំ២០១០ ដែលមានលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដោយមានអាជ្ញាធរភូមិ ឃុំ ទទួលដឹងលឺ ។ ស្រាប់តែក្នុងថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧ មន្ត្រីរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អភិបាលរងខេត្តកណ្តាល និងមន្ត្រីសុរិយោដីខេត្តកណ្តាល បានចុះអនុវត្ត ស.ជ.ណ លេខ ២៣ និងលេខ ០៦២ ពាក់ព័ន្ធនឹងដីរបស់ ឯកឧត្តម [redacted] ហួរ ដែលមានព្រំប្រទល់ជាប់នឹងដីរបស់ខ្លួន ។ ពេលដែលគណៈកម្មការធ្វើការវាស់វែង ស្រាប់តែមានឈ្មោះ [redacted] សុធារី បានចេញមកចង្អុលបង្ហាញគណៈកម្មការថា ដីទំហំ ១៦៧,០៥០២ហិកតា ជាដីរបស់គាត់ទៅវិញ ។ ពេលដែលខ្លួនដឹង ខ្លួនក៏បានចុះទៅហាមឃាត់ជាមួយប្រជាពលរដ្ឋ ពេលនោះគណៈកម្មការក៏បានផ្អាកការវាស់វែង ។ លុះដល់ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ គណៈកម្មការដែលដឹកនាំដោយលោក [redacted] ច័ន្ទតីរ៉ា អភិបាលរងខេត្តកណ្តាល សុំធ្វើការវាស់វែង ហើយឱ្យខ្លួនដាក់ពាក្យបណ្តឹងតវ៉ា ។ បន្ទាប់មកខ្លួនក៏បានដាក់ពាក្យបណ្តឹងមកសាលាខេត្តកណ្តាល, ភូមិបាលស្រុកកៀនស្វាយ, មន្ទីរដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តកណ្តាល, ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់, ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ស្រាប់តែមន្ទីរដែនដីខេត្តកណ្តាល កសាងនីតិវិធីធ្វើបណ្ណដីខ្លួនដែលក្បាលដីលេខ ៩ ដាក់ឈ្មោះ [redacted] សុធារី ។ នៅក្នុង ស.ជ.ណ ចង្អុលបង្ហាញការវាស់វែង តែនៅដីរបស់ឯកឧត្តម [redacted] ហួរ ស្ថិតនៅក្នុងភូមិកណ្តាលលើ និងភូមិកណ្តាលក្រោម ស្រាប់តែវាស់ចូលនៅដីភូមិខ្សុំ (ភូមិអង្គរជ័យ) ចូលនៅក្នុងដីរបស់ខ្លួនតែម្តង ។ ឈ្មោះ [redacted] សុធារី ពុំមានដីនៅក្នុងភូមិខ្សុំ (ភូមិអង្គរជ័យ) នោះឡើយ ។ ខ្លួនសំណូមពរសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ និងទាមទារសំណងជម្ងឺចិត្តចំនួន ៥០០ លានរៀល ។

២. សាក្សី ឈ្មោះ [redacted] វង្ស បានឆ្លើយបំភ្លឺថា: បច្ចុប្បន្នខ្លួនជាមេភូមិអង្គរជ័យ ហើយខ្លួនជាអតីតអនុប្រធានភូមិខ្សុំ ។ ខ្លួនស្គាល់ឈ្មោះ [redacted] ផូហុង ដោយសារគាត់បានទិញដីពីប្រជាពលរដ្ឋភូមិអង្គរជ័យ ។ ចំពោះដីដែលមានក្នុងភូមិអង្គរជ័យ មិនមានឈ្មោះ [redacted] សុធារី ចុះមកទិញទេ ។ ចំពោះព្រំប្រទល់ភូមិនីមួយៗតិមេឃុំជាអ្នកបែងចែក ខ្លួនមិនបានដឹងអំពីរឿងនេះទេ ។ ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] សុធារី ទេ ។

៣. សាក្សី ឈ្មោះ [redacted] លីស បានឆ្លើយបំភ្លឺថា: ខ្លួនជាមេភូមិកណ្តាលលើ ។ ខ្លួនស្គាល់ឈ្មោះ [redacted] ផូហុង ដោយសារគាត់ជាអ្នកទិញដីនៅភូមិកណ្តាលលើ និងភូមិអង្គរជ័យ ។ ចំពោះដីក្នុង ស.ជ.ណ លេខ ២៣



Scanned with CamScanner

ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាល ជាដីក្នុងទំនប់របស់ឯកឧត្តម [redacted] ហួរ ដែលត្រូវដកមកបែងចែកជូនប្រជាពលរដ្ឋវិញ តែខ្លួនមិនមានឯកសារទេ ។ ចំពោះព្រំប្រទល់ភូមិក្នុងឃុំបន្ទាយដែកកន្លងមកកាត់ដោយថ្នល់ និងប្រឡាយ (ប្រឡាយដែលមានតាំងពីជំនាន់ ប៉ុល ពត ចំនួន ០៣ ខ្សែ មិនចាំឈ្មោះ មិនដឹងថានរណាជាអ្នកជីក ហើយក៏មិនដឹងថាជីកនៅឆ្នាំណាដែរ) ។

៤. លោកស្រី [redacted] មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជូរហុង ធ្វើសេចក្ដីសន្និដ្ឋានថា: តាមការសួរដេញដោលឃើញថា ដីទំហំ ១៦៧,០៥០២ ហិកតា ដែលមានទីតាំងស្ថិតនៅភូមិខ្សុំ (បច្ចុប្បន្នជាភូមិអង្គរជ័យ) ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល កូនក្ដីរបស់ខ្លួនបានទិញពីប្រជាពលរដ្ឋតាំងពីឆ្នាំ២០១០ ដែលមានលិខិតផ្ទេរសិទ្ធិ គ្រប់គ្រង និងប្រើប្រាស់ដីធ្លី ទទួលស្គាល់ដោយរាជធានីភូមិឃុំ ហើយគាត់កាន់កាប់ឥតមានការអាក់ខានឡើយ ។ ប៉ុន្តែនៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧ មន្ត្រីរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាល អភិបាលរងខេត្តកណ្ដាល និងមន្ត្រីរបស់មន្ទីរសុរិយោដីខេត្តកណ្ដាល បានចុះអនុវត្ត ស.ជ.ណ លេខ ២៣ និងលេខ ០៦២ ពាក់ព័ន្ធនឹងដីរបស់ឯកឧត្តមឡោក ហួរ ដែលមានព្រំប្រទល់ជាប់នឹងដីរបស់កូនក្ដីខ្លួន ស្រាប់តែជនជាប់ចោទឈ្មោះ [redacted] សុធារី បានចេញមកចង្អុលបង្ហាញគណកម្មការធ្វើការវាស់វែង ពេលដែលគណកម្មការកំពុងធ្វើការវាស់វែងថា ដីទំហំ ១៦៧,០៥០២ ហិកតា ជាដីរបស់គាត់ទៅវិញ ។ ពេលដែលកូនក្ដីខ្លួនដឹងដំណឹងនេះ គាត់ក៏បានចុះទៅហាមឃាត់ជាមួយប្រជាពលរដ្ឋ ហើយគណកម្មការក៏បានផ្អាកការវាស់វែង ។ រហូតដល់ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ គណៈកម្មការដែលដឹកនាំដោយលោក ខឹម ច័ន្ទតិរី អភិបាលរងខេត្តកណ្ដាល សុំធ្វើការវាស់វែង និងបានឲ្យកូនក្ដីខ្លួនដាក់ពាក្យប្ដឹងតវ៉ា ។ ក្រោយពីកូនក្ដីខ្លួនបានដាក់ពាក្យប្ដឹងទៅតាមក្រសួង ស្ថាប័ននានារួចហើយស្រាប់តែមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាល បានកសាងនីតិវិធីធ្វើប័ណ្ណដីរបស់កូនក្ដីខ្លួន ដែលមានក្បាលដីលេខ ៤ ដាក់ឈ្មោះ [redacted] សុធារី ជាម្ចាស់កម្មសិទ្ធិ ដែលការចេញប័ណ្ណកម្មសិទ្ធិនេះ ផ្ទុយពីទំហំដីដែលមាននៅក្នុង ស.ជ.ណ លេខ ២៣ និងលេខ ០៦២ ទាំងស្រុង ព្រោះនៅក្នុងខ្លឹមសាររបស់ ស.ជ.ណ ខាងលើ បានចង្អុលបង្ហាញការវាស់វែង តែនៅលើដីរបស់ឯកឧត្តម [redacted] ហួរ ស្ថិតនៅក្នុងភូមិកណ្ដាលលើ និងភូមិកណ្ដាលក្រោមតែប៉ុណ្ណោះ ប៉ុន្តែគណៈកម្មការវាស់វែង ដែលមានការចង្អុលបង្ហាញពីសំណាក់ជនជាប់ចោទឈ្មោះ [redacted] សុធារី បានធ្វើការវាស់វែងចូលដល់ដីភូមិខ្សុំ (ភូមិអង្គរជ័យសព្វថ្ងៃ) តែម្ដង ។ មិនតែប៉ុណ្ណោះ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ លោក [redacted] ចាន់សុភី ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាល បានបញ្ជាក់ក្នុងកិច្ចប្រជុំដោះស្រាយវិវាទដីនេះ បានបញ្ជាក់ថា "ដីដែល លោក [redacted] ជូរហុង និងប្រជាជនចំនួន ១៤ គ្រួសារទៀតប្ដឹង កំពុងដោះស្រាយទំហំ ជាង ២០០ហិកតានេះ សូមទុក សមត្ថកិច្ចដោះស្រាយជូនតុលាការចុះ ព្រោះទោះបីជាប្លង់មិនទាន់បានប្រគល់ឲ្យឈ្មោះ [redacted] សុធារី ក៏ដោយ តែបានចេញទិន្នន័យក្បាលដីលេខ ៤ នេះ ដាក់ឈ្មោះ [redacted] សុធារី ចំនួន ១៥៧,៣២៨៨ ម៉ែត្រការ៉េ ទៅហើយ" ។ នេះសរបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុធារី ពិតជាមានចេតនាទុច្ចរិត ផ្ដល់សក្ខីកម្មមិនពិត បំភាន់មន្ត្រីសុរិយោដី ឲ្យធ្វើការវាស់វែង និងកសាងប័ណ្ណកម្មសិទ្ធិឲ្យខ្លួន នៅលើដីទំហំ ១៦៧,០៥០២ ហិកតា ដែលជាដីកម្មសិទ្ធិរបស់កូនក្ដីខ្លួនឈ្មោះ [redacted] ជូរហុង ដែលជាមូលហេតុធ្វើឲ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដូច្នេះ ស្នើសុំឲ្យតុលាការពិចារណា និងសម្រេចផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុធារី លើករណីបំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម ។

៥. តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ តាមការសួរដេញដោល ឃើញថាជនជាប់ចោទឈ្មោះ [redacted] សុធារី ពិតជាបានប្រព្រឹត្តអំពើ **បំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម** ប្រព្រឹត្តនៅភូមិអង្គរ

ជ័យ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥២ នៃច្បាប់ភូមិបាល ប្រាកដមែន ។

៦. លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុធារី បានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីការសិក្សា និងស្វែងយល់អង្គហេតុ អង្គច្បាប់ និងភស្តុតាងរួចមកខ្លួនសូមធ្វើការសន្និដ្ឋានថា អំពីប្រវត្តិនៃការកាន់កាប់ដី ឃើញថាកូនក្តីរបស់ខ្លួន ពិតជាម្ចាស់កម្មសិទ្ធិករលើដីស្របច្បាប់ដែលមានឯកសារបញ្ជាក់ និងមានប្លង់បង្ហាញទីតាំងដីច្បាស់លាស់ ដោយមានការទទួលស្គាល់ពីអាជ្ញាធរភូមិ ឃុំ ស្រុក តាំងពីឆ្នាំ២០០៥ មកម្លេះ និងតាមរយៈលិខិតរបស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល បានចេញប្លង់បង្ហាញអំពីការកំណត់ទីតាំងភូមិសាស្ត្រ និងព្រំប្រទល់ រួមទាំងបានធ្វើរបាយការណ៍គោរពជូនអភិបាលខេត្តកណ្តាល ដោយបានបង្ហាញឲ្យឃើញច្បាស់ថាដីរបស់កូនក្តីខ្លួនពិតជាមានទីតាំងស្ថិតនៅភូមិអង្គរជ័យ និងភូមិកណ្តាលលើ ហើយភូមិទាំងពីរមានព្រំប្រទល់ជាប់គ្នា និងបានបញ្ជាក់ថាទីតាំងដីដែលបានចុះវាស់វែងតាមការចង្អុលបង្ហាញរបស់ភាគីលោក តាន់ ជួរហុង បានត្រួតជាន់គ្នាលើដីមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖ ០៨០២០១០២-០០០៨ របស់ឈ្មោះ [redacted] សុធារី ដែលជាកូនក្តីខ្លួនពិតប្រាកដមែន ។ ចំពោះការវាស់វែងរបស់គណៈកម្មការថ្នាក់ជាតិ គឺអនុវត្តតាម ស.ជ.ណ របស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ២៣ សជណ.ឧស ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧ និងលិខិតជូនដំណឹងរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី លេខ ០៦២ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧ ដោយបានប្រកាសឲ្យប្រជាពលរដ្ឋដែលមានវិវាទដីជាមួយឯកឧត្តម [redacted] ហ៊ឺរ ដែលរាជរដ្ឋាភិបាលបានដោះស្រាយរួច ដែលមានទីតាំងស្ថិតនៅស្រុកកៀនស្វាយ ក្នុងភូមិកណ្តាលក្រោម និងភូមិកណ្តាលលើ ព្រមទាំងភូមិផ្សេងទៀត ដែលមានវិវាទក្នុងខេត្តកណ្តាលឲ្យចូលរួមសហការ និងដាក់ភ្ជាប់ឯកសារដើម្បីគណៈកម្មការថ្នាក់ជាតិធ្វើការវាស់វែងជូនជាលក្ខណៈប្រព័ន្ធ ។ ចំពោះការចោទប្រកាន់របស់ឈ្មោះ [redacted] ជួរហុង តាមពាក្យបណ្តឹង និងការចោទប្រកាន់របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល មកលើកូនក្តីខ្លួន ពីបទបំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម គឺពុំមានភស្តុតាងណាមួយដែលបញ្ជាក់ថាកូនក្តីខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
-ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

**ក/ អំពីពិរុទ្ធភាព**

១- តាមដីកាដំណោះស្រាយលេខ ៩៣១ ដកសស ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុធារី (អត្តសញ្ញាណខាងលើ) ជាប់ចោទពីបទ: **បំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម** ប្រព្រឹត្តនៅភូមិអង្គរជ័យ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥២ នៃច្បាប់ភូមិបាល ។

២- តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ផូរហុង បង្ហាញឱ្យឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] សុធារី ពិតជាបាន បំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម ប្រាកដមែន ដោយជនជាប់ចោទបាន ចង្អុលបង្ហាញដល់មន្ត្រីសុរិយោដីខេត្តកណ្តាល នូវដីដែលជាកម្មសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីថា ជាដីកម្មសិទ្ធិរបស់ខ្លួន និងស្នើសុំឲ្យមានការចេញប័ណ្ណកម្មសិទ្ធិទៀត ។

៣. តាមការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី ឃើញថា ដីទំហំ ១៦៧,០៥០២ ហិកតា ដែលមានទីតាំងស្ថិតនៅភូមិឪឡុំ (បច្ចុប្បន្នជាភូមិអង្គរជ័យ) ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កូនក្តីរបស់ខ្លួនបានទិញពីប្រជាពលរដ្ឋតាំងពីឆ្នាំ២០១០ ដែលមានលិខិតផ្ទេរសិទ្ធិ គ្រប់គ្រង និងប្រើប្រាស់ដីធ្លី ទទួលស្គាល់ដោយអាជ្ញាធរភូមិឃុំ ហើយគាត់កាន់កាប់ឥតមានការអាក់ខានឡើយ ។ ប៉ុន្តែនៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧ មន្ត្រីរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល អភិបាលរងខេត្តកណ្តាល និងមន្ត្រីរបស់មន្ទីរសុរិយោដីខេត្តកណ្តាល បានចុះអនុវត្ត ស.ជ.ណ លេខ ២៣ និងលេខ ០៦២ ពាក់ព័ន្ធនឹងដីរបស់ឯកឧត្តម ឡោក ហួរ ដែលមានព្រំប្រទល់ជាប់នឹងដីរបស់កូនក្តីខ្លួន ស្រាប់តែជនជាប់ចោទឈ្មោះ [redacted] សុធារី បានចេញមកចង្អុលបង្ហាញគណកម្មការធ្វើការវាស់វែង ពេលដែលគណកម្មការកំពុងធ្វើការវាស់វែងថា ដីទំហំ ១៦៧,០៥០២ ហិកតា ជាដីរបស់គាត់ទៅវិញ ។ ពេលដែលកូនក្តីខ្លួនដឹងដំណឹងនេះ គាត់ក៏បានចុះទៅហាមឃាត់ជាមួយប្រជាពលរដ្ឋ ហើយគណកម្មការក៏បានផ្អាកការវាស់វែង ។ រហូតដល់ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៧ គណៈកម្មការដែលដឹកនាំដោយលោក [redacted] ច័ន្ទគិរី អភិបាលរងខេត្តកណ្តាល សុំធ្វើការវាស់វែង និងបានឲ្យកូនក្តីខ្លួនដាក់ពាក្យប្តឹងតវ៉ា ។ ក្រោយពីកូនក្តីខ្លួនបានដាក់ពាក្យប្តឹងទៅតាមក្រសួង ស្ថាប័ននានារួចហើយ ស្រាប់តែមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល បានកសាងនីតិវិធីធ្វើប័ណ្ណដីរបស់កូនក្តីខ្លួន ដែលមានក្បាលដីលេខ ៤ ដាក់ឈ្មោះ [redacted] សុធារី ជាម្ចាស់កម្មសិទ្ធិ ដែលការចេញប័ណ្ណកម្មសិទ្ធិនេះ ផ្ទុយពីទំហំដីដែលមាននៅក្នុង ស.ជ.ណ លេខ ២៣ និងលេខ ០៦២ ទាំងស្រុង ព្រោះនៅក្នុងខ្លឹមសាររបស់ ស.ជ.ណ ខាងលើ បានចង្អុលបង្ហាញការវាស់វែង តែនៅលើដីរបស់ឯកឧត្តម [redacted] ហួរ ស្ថិតនៅក្នុងភូមិកណ្តាលលើ និងភូមិកណ្តាលក្រោមតែប៉ុណ្ណោះ ប៉ុន្តែគណៈកម្មការវាស់វែង ដែលមានការចង្អុលបង្ហាញពីសំណាក់ជនជាប់ចោទឈ្មោះ [redacted] សុធារី បានធ្វើការវាស់វែងចូលដល់ដីភូមិឪឡុំ (ភូមិអង្គរជ័យសព្វថ្ងៃ) តែម្តង ។ មិនតែប៉ុណ្ណោះ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ លោក [redacted] ចាន់ស្វាតិ ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល បានបញ្ជាក់ក្នុងកិច្ចប្រជុំដោះស្រាយវិវាទដីនេះ បានបញ្ជាក់ថា "ដីដែល លោក [redacted] ផូរហុង និងប្រជាជនចំនួន ១៤ គ្រួសារទៀតប្តឹង កំពុងដោះស្រាយទំហំ ជាង ២០០ហិកតា នេះ សូមទុក សមត្ថកិច្ចដោះស្រាយជូនតុលាការចុះ ព្រោះទោះបីជាប្លង់មិនទាន់បានប្រគល់ឲ្យឈ្មោះ [redacted] សុធារី ក៏ដោយ តែបានចេញទិន្នន័យក្បាលដីលេខ ៤ នេះ ដាក់ឈ្មោះ [redacted] សុធារី ចំនួន ១៥៧,៣២៨៨ ម៉ែត្រការ៉េ ទៅហើយ" ។ នេះសរបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុធារី ពិតជាមានចេតនាទុច្ចរិត ផ្តល់សក្ខីកម្មមិនពិត បំភាន់មន្ត្រីសុរិយោដី ឲ្យធ្វើការវាស់វែង និងកសាងប័ណ្ណកម្មសិទ្ធិឲ្យខ្លួន នៅលើដីទំហំ ១៦៧,០៥០២ ហិកតា ដែលជាដីកម្មសិទ្ធិរបស់កូនក្តីខ្លួនឈ្មោះ [redacted] ផូរហុង ដែលជាមូលហេតុធ្វើឲ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះ ស្នើសុំឲ្យតុលាការពិចារណា និងសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុធារី លើករណីបំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម ។

៤. តាមការសន្និដ្ឋានរបស់តំណាងអយ្យការ ឃើញថា ជនជាប់ចោទពិតជាបានចង្អុលបង្ហាញដល់មន្ត្រីសុរិយោដីក្នុងការវាស់វែង កសាងប័ណ្ណកម្មសិទ្ធិលើដីរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រាកដមែន ដូច្នេះតំណាង

អយ្យការនៅតែរក្សាការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] សុធាវី ពីបទ បំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម ប្រព្រឹត្តនៅភូមិអង្គរជ័យ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌចែងឱ្យផ្ដន្ទាទោសតាមមាត្រា ២៥២ នៃច្បាប់ភូមិបាល ។

៥. តាមការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ឃើញថា ក្រោយពីការសិក្សា និងស្វែងយល់អង្គហេតុ អង្គច្បាប់ និងភស្តុតាង រួចមកខ្លួនសូមធ្វើការសន្និដ្ឋានថា អំពីប្រវត្តិនៃការកាន់កាប់ដី ឃើញថាកូនក្ដីរបស់ខ្លួន ពិតជាម្ចាស់កម្មសិទ្ធិករលើដីស្របច្បាប់ដែលមានឯកសារបញ្ជាក់ និងមានប្លង់បង្ហាញទីតាំងដីច្បាស់លាស់ ដោយមានការទទួលស្គាល់ពីអាជ្ញាធរភូមិ ឃុំ ស្រុក តាំងពីឆ្នាំ២០០៥ មកម្ល៉េះ និងតាមរយៈលិខិតរបស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាល បានចេញប្លង់បង្ហាញអំពីការកំណត់ទីតាំងភូមិសាស្ត្រ និងព្រំប្រទល់ រួមទាំងបានធ្វើរបាយការណ៍គោរពជូនអភិបាលខេត្តកណ្ដាល ដោយបានបង្ហាញឲ្យឃើញច្បាស់ថាដីរបស់កូនក្ដីខ្លួនពិតជាមានទីតាំងស្ថិតនៅភូមិអង្គរជ័យ និងភូមិកណ្ដាលលើ ហើយភូមិទាំងពីរមានព្រំប្រទល់ជាប់គ្នា និងបានបញ្ជាក់ថាទីតាំងដីដែលបានចុះវាស់វែងតាមការចង្អុលបង្ហាញរបស់ភាគីលោក [redacted] ជូរហុង បានត្រួតជាន់ គ្នាលើដីមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖ ០៨០២០១០២-០០០៥ របស់ឈ្មោះ [redacted] សុធាវី ដែលជាកូនក្ដីខ្លួនពិតប្រាកដមែន ។ ចំពោះការវាស់វែងរបស់គណៈកម្មការថ្នាក់ជាតិ គឺអនុវត្តតាម ស.ជ.ណ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី លេខ ២៣ សជណ.ឧស ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧ និងលិខិតជូនដំណឹងរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី លេខ ០៦២ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧ ដោយបានប្រកាសឲ្យប្រជាពលរដ្ឋដែលមានវិវាទដីជាមួយឯកឧត្ដម ឡោក ហ៊ិវ ដែលរាជរដ្ឋាភិបាលបានដោះស្រាយរួច ដែលមានទីតាំងស្ថិតនៅស្រុកកៀនស្វាយ ក្នុងភូមិកណ្ដាលក្រោម និងភូមិកណ្ដាលលើ ព្រមទាំងភូមិផ្សេងទៀត ដែលមានវិវាទក្នុងខេត្តកណ្ដាលឲ្យចូលរួមសហការ និងដាក់ភ្ជាប់ឯកសារដើម្បីគណៈកម្មការថ្នាក់ជាតិធ្វើការវាស់វែងជូនជាលក្ខណៈប្រព័ន្ធ ។ ចំពោះការចោទប្រកាន់របស់ឈ្មោះ [redacted] ជូរហុង តាមពាក្យបណ្ដឹង និងការចោទប្រកាន់របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល មកលើកូនក្ដីខ្លួន ពីបទ បំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម គឺពុំមានភស្តុតាងណាមួយដែលបញ្ជាក់ថាកូនក្ដីខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ។

៦. តាម ស.ជ.ណ លេខ ២៣ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧ ដែលចេញដោយទីស្ដីការគណៈរដ្ឋមន្ត្រី មានខ្លឹមសារៈ

"...................... ដកហូតដីរបស់ឯកឧត្ដម [redacted] ហ៊ិវ ទំហំ ២ ៣៩១,៥០ ហិកតា ដែលរំលោភលើដីរបស់ប្រជាពលរដ្ឋ នៅស្រុកកៀនស្វាយ និងស្រុកស្អាង ខេត្តកណ្ដាល ................" ។

៧. តាម ស.ជ.ណ លេខ ០៦២ ដនស ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧ ដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានខ្លឹមសារៈ

"...................... **សុំចាត់ចែងជូនដំណឹងអំពីការចុះវាស់វែងប្រមូលទិន្នន័យ** ដើម្បីចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធជូនប្រជាពលរដ្ឋដែលមានវិវាទដីធ្លីជាមួយ ឯកឧត្ដម [redacted] ហ៊ុវ ហើយទើបត្រូវបានរាជរដ្ឋាភិបាលដោះស្រាយរួច ស្ថិតនៅក្នុងស្រុកកៀនស្វាយ ក្នុងភូមិកណ្ដាលក្រោម ភូមិកណ្ដាលលើ.............." ។

៨. តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ចម្លើយសាក្សី ព្រមទាំងភស្តុតាងនានា មានភាពស៊ីសង្វាក់គ្នា បង្ហាញឱ្យឃើញថា កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧ ជនជាប់ចោទឈ្មោះ [redacted] សុធាវី ពិតជាទៅចង្អុលបង្ហាញគណៈកម្មការសុរិយោដីថាដីទំហំ ១៦៧,០៥០២ ហិកតា ដែលមានទីតាំងស្ថិតនៅភូមិខ្សាំ (បច្ចុប្បន្នជាភូមិអង្គរជ័យ) ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ថាជាដីរបស់ខ្លួនប្រាកដមែន ដែលការចង្អុល



Scanned with CamScanner

បង្ហាញរបស់ជនជាប់ចោទទៅកាន់គណៈកម្មការសុរិយោដី ខុសពីទីតាំងដីដែលមាននៅក្នុង ស.ជ.ណ លេខ ២៣ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧ ដែលចេញដោយទីស្តីការគណៈរដ្ឋមន្ត្រី និងស.ជ.ណ លេខ ០៦២ ដនស ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧ ដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឈានទៅដល់ទីតាំងដីកម្មសិទ្ធិរបស់ឈ្មោះ [redacted] ជូរហុង ហើយផ្ទុយទាំងស្រុងពីខ្លឹមសារក្នុង ស.ជ.ណ ទាំងពីរខាងលើ ស្របនឹងការសន្និដ្ឋានរបស់តំណាងអយ្យការ ។

៩. អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុធារី បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសណ្តាប់ធ្នាប់សង្គម ។

១០. ជនជាប់ចោទមានស្មារតីធម្មតាអាចយល់ដឹងពីបច្ច័យកើតឡើងដែលបង្កឱ្យមានបទល្មើស ។

១១. មានភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សុធារី ពីបទៈ បំភាន់ មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម ប្រព្រឹត្តនៅភូមិអង្គរជ័យ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥២ នៃច្បាប់ភូមិបាល ។

**ខ/ អំពីវត្ថុចាប់យក**

- គ្មាន ។

**គ/ អំពីសំណង និងជម្ងឺចិត្ត**

- ទាមទារសំណងជម្ងឺចិត្តជាទឹកប្រាក់ ៥០០ (ប្រាំរយ) លានរៀល ។ គប្បីតុលាការ ពិចារណា ។

**ហេតុដូច្នេះសម្រេច**

១- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុធារី (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ) ខែ ។

ពីបទៈ បំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម ប្រព្រឹត្តនៅភូមិអង្គរជ័យ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥២ នៃច្បាប់ភូមិបាល។

២- បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សុធារី សងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៣០,០០០,០០០ (សាមសិបលាន) រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជូរហុង ឯការទាមទារលើសពីនេះ ច្រានចោល ។

សាលក្រមជំនុំជម្រះ នៅថ្ងៃទី០៨ មិថុនា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជូរហុង ប៉ុន្តែកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុធារី ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ**

**បានឃើញ**

០៩. មិ.ហ. ២០២១

**តំណាងអយ្យការ**

[redacted]

[redacted]

[redacted]

**ព្រះរាជអាជ្ញារង**

Scanned with CamScanner